# ការដឹកនាំវណ្ណៈសូទ្រនៅក្នុងក្រុមប្រឹក្សាភូមិថ្មី

ប្រព័ន្ធវណ្ណៈនៅតំបន់អាស៊ីខាងត្បូង ដែលហៅថា Dalit (ឬ វណ្ណៈសូទ្រ) ត្រូវបានគេដឹងកាលពីដំបូងឡើយថាជាវណ្ណៈអាក្រក់ដែលមិនអាចប៉ះពាល់បាន ឬ ហៅថា *achuta* គឺជាក្រុមមនុស្សដែលស្ថិតនៅក្រៅ Varnas (វណ្ណៈ) ទាំងបួន ហើយត្រូវបានគេចាត់ទុកថា ជាមនុស្សថ្នាក់ទាបជាងគេបំផុត និងមិនមានភាពស្អាតស្អំ។ Varna គឺជាប្រព័ន្ធឋានានុក្រមមុខងារដែលត្រូវបានស្នើឡើងនៅក្នុងឯកសារឥណ្ឌាជំនាន់ដើម ដើម្បីធ្វើការ រៀបចំសង្គម ហើយក្រោយមកទៀតវាបានវិវឌ្ឍទៅជាប្រព័ន្ធវណ្ណៈនៅក្នុងប្រទេសឥណ្ឌា។ វណ្ណៈសូទ្ររួមមាន កម្មករធ្វើការងារពាក់ព័ន្ធនឹងស្បែកសត្វ អ្នកដើររើសអេតចាយ អ្នកកែច្នៃស្បែកសត្វធ្វើសម្ភារផ្សេងស១ អ្នក ពន្លាត់ស្បែកសត្វ អ្នកជួសជុលស្បែកជើង កម្មករធ្វើការងារកសិកម្ម អ្នកសម្អាតនៅតាមទីក្រុង អត្តពលលិក អ្នកវាយស្គរ អ្នកតន្ត្រីប្រជាប្រិយ និងសិប្បករធ្វើការតាមចិញ្ចើមថ្នល់។

ការផ្តល់ឱ្យនូវការរៀបចំវណ្ណៈសូទ្រនៅក្នុង panchayats (ក្រុមប្រឹក្សាភូមិ) ថ្មី ដែលបង្កើតឡើងដោយច្បាប់វិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី ៧៣ ក្នុងឆ្នាំ១៩៩៣ នៅក្នុងប្រទេសឥណ្ឌា គឺជាការផ្លាប់ប្តូរដ៏សំខាន់បំផុតមួយក្នុងចំណោការផ្លាប់ប្តូរផ្សេងៗទៀតដែលត្រូវបានណែនាំនៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ ក្រៅពីកៅអីរបស់ពួកវណ្ណៈសូទ្រនៅក្នុងក្រុមប្រឹក្សាឃុំនីមួយៗដោយផ្អែកទៅលើចំនួនប្រជាជនរបស់ពួកគេ តំណែងរបស់ប្រធានភូមិ (Sarpanch) បូករួមនឹងចំនួនកៅអី ១/៣ (មួយភាគបី) សម្រាប់ស្ត្រីនៅក្នុងវណ្ណៈសូទ្រត្រូវបានគេរក្សាទុក។ បទបញ្ញត្តិទាំងនេះមានសក្តានុពលក្នុងការលើកកម្ពស់នូវភាពជាអ្នកដឹកនាំថ្មីមួយ ក្នុង ចំណោមវណ្ណៈសូទ្រដែលដើរតួយ៉ាងសំខាន់ក្នុងការចូលរួម និងធ្វើសេចក្តីសម្រេចិត្តនៅក្នុងក្រុមប្រឹក្សាភូមិថ្មីៗ។ លើសពីនេះទៀត វិសោធនកម្មនេះបានផ្តល់ឱ្យក្រុមប្រឹក្សាភូមិនូវឋានៈនៅក្នុងរដ្ឋធម្មនុញ្ញ ដែលបានធ្វើ ឱ្យពួកគេក្លាយទៅជាថ្នាក់ទី ៣ នៅក្នុងរចនាសម្ព័ន្ធសហព័ន្ធ។ ភាពខុសប្រក្រតីនៃស្ថាប័នផ្សេងៗដែលកើត មាននៅក្នុងពេលអត្តីតកាលត្រូវបានគេលុបបំបាត់ចោល ដោយធ្វើការបោះឆ្នោតជាទៀងទាត់ ហើយអំណាច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភូមិត្រូវបានពង្រីក និងបានកំណត់យ៉ាងច្បាស់លាស់ លើសពីនេះទៀត គណៈកម្មការហិរញ្ញវត្ថុរដ្ឋត្រូវបានបង្កើតឡើងដើម្បីផ្តល់ហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់។ ក្រុមប្រឹក្សាភូមិបានរួប រួមគ្នាជាថ្នាក់ដ៏សំខាន់មួយនៅក្នុងរចនាសម្ព័ន្ធសហព័ន្ធ និងដើរតួយ៉ាងជាក់លាក់នៅក្នុងគោលនយោបាយរដ្ឋ និងមានសមត្ថភាពអនុវត្តន៏ការងារអភិវឌ្ឍតាមថ្នាក់មូលដ្ឋាន។ ហេតុនេះហើយ ការរៀបចំនៅថ្នាក់ក្រុមប្រឹក្សា ភូមិនាពេលបច្ចុប្បន្ននេះមានផលប្រយោជន៏កាន់តែសំខាន់ នៅក្នុងការចូលរួមផ្នែកនយោបាយសម្រាប់វណ្ណៈ សូត្រជាងនៅក្នុងអង្គនីតិបញ្ញត្តិថ្នាក់កណ្តាល និងរដ្ឋ។ វាបានបើកចំហទ្វារសមរភូនិយោបាយ ដើម្បីឱ្យមាន ការលាយបញ្ចូលគ្នានូវអ្នកដឹកនាំវណ្ណៈសូទ្រទៅក្នុងនយោបាយប្រជាធិបតេយ្យ និងណែនាំឱ្យមានការផ្លាប់ប្តូរ នៅថ្នាក់មូលដ្ឋាន។

តាមប្រពៃណី ការដឹកនាំនៅក្នុងភូមិដោយប្រកាន់ខ្ជាប់តាម "វិរជននៅតាមជនបទ" ដែលត្រូវបានគេនិយាយជាទូទៅនោះ វាចាស់កម្រិល និងបង្ហាញពីការអប់រំកម្រិតទាប ពាក់ព័ន្ធនឹងវណ្ណៈខ្ពស់ជាង ជាមួយនឹងការផ្សាភ្ជាប់ទៅនឹងអ្នកដឹកនាំនយោបាយ និងការិយាធិបតេយ្យ (Chakraborty និង Bhattacharyya, 1993) នោះ។ ជាគោលការណ៍ លក្ខណៈសម្បត្តិជាវិរជននេះ គឺផ្អែកទៅលើកម្មសិទ្ធិលើដីធ្លី គឺមិនមែនគ្រាន់តែផ្អែកលើ ប្រភពសំខាន់ដែលអាចរស់បាននៅតាមថ្នាក់ភូមិនោះទេ ប៉ុន្តែវាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការកំណត់ នូវប្រព័ន្ធលំដាប់ថ្នាក់នៅតាមតំបន់ជនបទ និងរចនាសម្ព័ន្ធអំណាច (Beteille, 1974)។ វាបានបង្កើតឱ្យមាន ភាពពឹងផ្អែកសម្រាប់កម្មករក្នុងវណ្ណៈទាបជាងដែលមិនមានដីធ្លីទៅលើវណ្ណៈដែលមានសិទ្ធិកាន់កាប់ដីធ្លីច្រើនជាងនោះ។ ឋានានុក្រមវណ្ណៈតាមប្រពៃណីបានដាក់វណ្ណៈសូទ្រនៅបាតក្រោមគេ ហើយបានបណ្ដុះទំលាប់ឱ្យ មានភាពផ្សេងគ្នារវាងវណ្ណៈទាបជាង និងវណ្ណៈខ្ពស់ជាងក្នុងចំណោមមនុស្សវ័យក្មេងរហូតដល់វ័យចំណាស់ កម្មករធ្វើការងារកសិកម្មដែលមិនមានដីធ្លីត្រូវគោរពតាមម្ចាស់ដីដោយគ្មានល័ក្ខខ័ណ្ឌ ហើយអ្នកក្រត្រូវតែ ធ្វើតាមអ្នកមានទ្រព្យធន។ កត្តាទាំងអស់នេះបានធ្វើឱ្យ "ស្របច្បាប់" នូវការអនុវត្តអំណាចពីសំណាក់វណ្ណៈ កាន់កាប់ដីធ្លីមានអំណាច និងមានទ្រព្យធនច្រើនជាងនៅក្នុងភូមិ។ រចនាសម្ព័ន្ធអំណាចនៅតាមភូមិអនុវត្តទៅ តាមទម្រង់ការដឹកនាំ ភាពគ្រប់គណ្ដប់ការប្រើឥទ្ធិពល ការគ្រប់គ្រងបញ្ហា ឬ អនុវត្តក្នុងទម្រង់ដ៏អាក្រក់របស់គេ ហើយបានបង្ហាញឱ្យឃើញ យ៉ាងច្បាស់នូវការប្រើប្រាស់កម្លាំងប្រកបដោយភាពអមនុស្សធម៌ ឬ ការបង្ខិតបង្ខំលើរាងកាយពីសំណាក់ក្រុមនេះ។ ការសិក្សាក៏បានបង្ហាញផងដែរនូវក្រុមពីរនៅក្នុងភូមិ ដែលជាញឹកញាប់ ត្រូវបានដឹកនាំដោយអ្នកមានវណ្ណៈខ្ពស់បំផុតនិងមានអ្នកដើរតាមដែលមកពីក្រុមមានវណ្ណៈទាបជាង។ ដូច្នេះហើយ មេដឹកនាំក្រុមបានដឹកនាំភូមិ និងនយោបាយក្នុងចំណោមពួកគេនោះ (Chakraborty និង Bhatta- charyya, 1993)។ ទម្រង់ថ្មីៗនៃការគាបសង្កត់ដោយកម្លាំងវណ្ណៈ និងតាមកម្រិតថ្នាក់បានបង្ហាញជារួមនូវ អំណាចដែលមាននៅក្នុងដៃរបស់អ្នកមានវណ្ណៈខ្ពស់ជាង និងការគាបសង្កត់ទៅលើអ្នកមានវណ្ណៈទាបជាងចេះតែបន្ត (Beteille, 1974; Srinivas, 1960)។

ក្នុងទិដ្ឋភាពនេះ ការផ្លាស់ប្តូរសង្គមយ៉ាងឆាប់រហ័ស ដែលបានធ្វើឡើងនៅតាមតំបន់ជនបទបាននាំក្រុមអ្នកដឹកនាំដែលមានសមត្ថភាពកាន់ការងារដោយងាយស្រួល ទាំងនីតិវិធីការិយាធិបតេយ្យ និងការទំនាក់ទំនងផ្ទាល់ខ្លួន ឱ្យទៅដោះស្រាយជម្លោះផ្សេងៗ ពេលគេដោះស្រាយរឿងរ៉ាវទាំងនោះបាន គេមានឥទ្ធិពលលើអ្នកដទៃទៀត។ អំណាចរបស់ពួកគេត្រូវបានកំណត់ដោយរចនាសម្ព័ន្ធវណ្ណៈតាមប្រពៃណី ដោយសារតែពួកគេជាក្រុម ដែលមានវណ្ណៈខ្ពស់ជាង។ អ្នកដឹកនាំមានសមត្ថភាពធ្វើការងារទាំងនេះ គឺដោយសារតែគេតម្រូវឱ្យមានការ គោរពតាម ឬដោយសារតែអំណាចគេបានគ្រប់ដណ្តប់ទៅលើអ្នកភូមិទាំងអស់។ អ្វីដែលយើងបានរកឃើញនោះ គឺការកើតឡើងស្របគ្នានូវប្រភេទពីរនៃប្រព័ន្ធសង្គម ហើយប្រភេទនីមួយៗមានលក្ខណៈនៃការរៀបចំ និងបែបបទផ្ទាល់របស់វា។ ប្រភេទទីមួយត្រូវបានរៀបចំឡើងពាក់ព័ន្ធនឹងវណ្ណៈ ភាពជាសាច់ញាតិ និងទំនាក់ទំនងសហគមន៍

ជាមួយការឱ្យតម្លៃខ្ពស់ទៅលើភក្ដីភាពផ្ទាល់ខ្លួន និងចំណងនៃការពឹងផ្អែកផ្ទាល់ខ្លួន។ ទន្ទឹមគ្នា នេះដែរ ប្រភេទទីពីរ គឺទំនាក់ទំនងនៃការរៀបចំ ឬ "ការិយាល័យ" ដែលជាគោលការណ៍ វាជាកន្លែងដែល ការជាប់ទាក់ទងគ្នា ត្រូវបានគ្រប់គ្រងដោយការឱ្យតម្លៃ និងបទដ្ឋានពីខាងក្រៅ។ នៅក្នុងប្រទេសឥណ្ឌា ដោយ សារតែភូមិនានា នៅតែត្រូវបានរៀបចំតាមរយៈចំណងនៃវណ្ណៈ និងភាពជាសាច់ញាតិ ទើបប្រទេភទាំងពីរ នេះនៅតែជាប់ទាក់ទង និងពង្រឹងគ្នាទៅវិញទៅមកដដែល ដោយហេតុថា ពួកគេមានការរំពឹងថា អ្នកដឹកនាំ នោះនឹងជួយសាច់ញាតិ នៅក្នុងវណ្ណៈរបស់ពួកគេ ហើយប្រើអំណាចក្នុងនាមវណ្ណៈពួកគេផ្ទាល់។

ទំនាក់ទំនងតាមខ្សែបញ្ឈរនេះកំពុងតែឆ្លងកាត់ការផ្លាប់ប្តូរ ហើយវាកាន់តែមានការលំបាកសម្រាប់អ្នកដឹកនាំ នៅក្នុងវណ្ណៈខ្ពស់បំផុតនាពេលបច្ចុប្បន្ននេះក្នុងការគ្រប់គ្រងលើរចនាសម្ព័ន្ធអំណាចថ្នាក់ភូមិ និងក្នុងការទាញ យកការគោរពពីសំណាក់អ្នកមានវណ្ណៈទាបជាងនោះ។ ការអនុវត្តអំណាច គឺវាលែងតពូជ ដែលផ្ទេរឱ្យដោយ ស្វ័យប្រវត្តិ និងដោយគ្មានការប្រកួតប្រជែងនោះទៀតហើយ។ ដោយមានការណែនាំពីលិទ្ធិប្រជាធិបតេយ្យ មនុស្សពេញវ័យ នៅលើពិភពលោកមានសិទ្ធិបោះឆ្នោត និងការធ្វើវិមជ្ឈការរបបប្រជាធិបតេយ្យតាមរយៈ PRIs (ស្ថាប័ន Panchayati Raj) ជាមូលដ្ឋាននៃអំណាច ហើយការអនុវត្តរបស់ខ្លួនបានឆ្លងកាត់ការផ្លាប់ប្តូរ គួរឱ្យកត់សម្គាល់។ ប្រភព និងទម្រង់ថ្មីៗនៃអំណាចបានលាយបញ្ចូលគ្នា បើទោះនៅពេលទន្ទឹមគ្នានេះ ប្រភព និងទម្រង់ចាស់ មិនទាន់សាបរលាបបាត់នៅឡើយក្តី។ ការដឹកនាំមានការទាក់ទនងគ្នាយ៉ាងជិតស្និទ្ធ ហើយគេ មិនអាចយល់បានឡើយ ក្រៅពីធ្វើឱ្យការផ្លាស់ប្តូរទាំងនេះកើតឡើងនៅក្នុងសង្គម។ គេអាចនឹងលែងសិក្សា វាតាមគំរូដែលមានការពឹងផ្អែកដ៏លើសលប់ទៀតហើយ។ អ្នកប្រាជ្ញបានបង្ហាញនូវជំហានចំនួន ៣ គឺ តាម ប្រពៃណី ការផ្សារភ្ជាប់ និងប្រជាធិបតេយ្យ។ នៅក្នុងដំណាក់កាលប្រពៃណី គឺវាហាក់ដូចជាទូទៅហើយ ដែលថា រចនាសម្ព័ន្ធនយោបាយនឹងត្រូវស្ថិតនៅក្នុងកណ្តាប់ដៃមនុស្សមួយក្រុមតូច ហើយអ្នកមានវណ្ណៈខ្ពស់ នឹងដឹកនាំគេ ចំណែកឯប្រជាជនសាមញ្ញ និងអ្នកមានវណ្ណៈទាបជាងនឹងមិនមានឱកាសទទួលបានតំណែងដែល មានអំណាចនោះឡើយ។ នៅក្នុងដំណាក់កាលទីពីរភាពមានគំនិតផ្ទុយគ្នាបានលេចចេញ ហើយអត្តសញ្ញាណប្រពៃណីនឹងឈានទៅចុះខ្សោយ ដោយសារតែការទទួលបាននូវការអប់រំ និងធនធាន។ ទោះជាយ៉ាងណាក៏ ដោយកម្លាំងនៃការរិះគន់ត្រូវតែស្ថិតក្នុងការគ្រប់គ្រង។ នេះគឺជាជំហានមួយនៃគោលនយោបាយប្រជាធិប តេយ្យ និងវណ្ណៈអភិជន។ ជំហាននេះត្រូវបានគាំទ្រដោយដំណាក់កាលប្រជាធិបតេយ្យ ជាចំណុចដែលវណ្ណៈជាមូលដ្ឋានគ្រឹះមួយបន្តមានសារៈសំខាន់ ប៉ុន្តែបាត់បង់នូវតួនាទីស្របតាមច្បាប់ប្រពៃណីរបស់វា ហើយបានក្លាយទៅជាចំណុចដែលអាចផ្លាស់ប្តូរបាននៅក្នុងចំណោមនោះ។ អ្នកប្រាជ្ញបានលើកឡើងថា នៅក្នុងប្រទេសឥណ្ឌា ដំណើរការនេះ គឺមានដំណើរការទៅមុខហើយ ប៉ុន្តែវាមានកម្រិតផ្សេងៗគ្នានៅក្នុងតំបន់ផ្សេងៗ ដែលជាហេតុធ្វើឱ្យដំណើរការនេះកាន់តែមានភាពស្មុគស្មាញខ្លាំង (Shiviah

et al., 1978: 122-23)។

រហូតមកដល់ពេលនេះ ក្រុមប្រឹក្សាភូមិទាំងនេះមានអាយុមួយទសវត្សរ៍ហើយ ហើយស្ទើរតែគ្រប់រដ្ឋទាំងអស់ គេបានធ្វើការបោះឆ្នោតចំនួនពីរដង ចាប់តាំងពីបានអនុមត្តិច្បាប់នេះមក។ ពាក់ព័ន្ធនឹងចំនួនពិតប្រាកដ អ្នក តំណាងដែលជាប់ឆ្នោះចំនួនយ៉ាងច្រើនបានតំណាងឱ្យការផ្លាប់ប្តូរប្រកបដោយនិរន្តរភាពនៅក្នុងការចងក្រង ក្រុមប្រឹក្សាភូមិ។ ការអនុមត្តិការធ្វើវិសោធនកម្មលើទី ៧៣ បានជំរុញឱ្យមានការផ្លាប់ប្តូរមួយចំនួនធំ ដែល បានកើតឡើងទាំងនៅក្នុងសហគមន៍វណ្ណៈសូទ្រ និងនៅក្នុងសង្គមឥណ្ឌា ព្រមទាំងនៅក្នុងការរៀបចំនយោ បាយផងដែរ។ នៅទសវត្សរ៍ឆ្នាំ១៩៨0 បានបង្ហាញឱ្យឃើញការជំរុញដំណើរការរយៈពេលវែងនៃការធ្វើប្រជាធិបតេយ្យូបនីយកម្ម និងការធ្វើតំបន់ភាវូបនីយកម្មដែលបានដាក់ចេញដោយសង្គមប្រជាធិបតេយ្យ និងការ រៀបចំដំណើរការនយោបាយនៅក្នុងអំឡុងរបបសារធាណៈរដ្ឋ។ អ្នកប្រាជ្ញមួយចំនួនធំបានគូសបញ្ជាក់ថា អំណាចវរជននៅតាមជនបទនៅតែជាកង្វល់នៅឡើយ ដោយសារតែវាមិនទាន់រលាយសាបសូន្យ។ ក្នុងអត្ថបទសរសេរនៅដើមទសសវត្សរ៍ឆ្នាំ ១៩៩0 Mendelsohn បានបញ្ជាក់ថា ទន្ទឹមនឹងមានការអភិវឌ្ឍសេដ្ឋកិច្ច ការអបរំ និងការផុះចេញនូវទម្រង់ថ្មីៗនៃការងារមិនមែនកសិកម្ម ដីធីវាលែងជាប្រភពតែមួយគត់ នៃអំណាច និងកិត្យានុភាពនៅក្នុងប្រទេសឥណ្ឌាទៀតហើយ (Mendelsohn, 1993: 804-42)។ ស្រដៀង គ្នានេះដែរ ការសិក្សានាពេលថ្មីៗរបស់ UP ភាគខាងលិច បង្ហាញថា រចនាសម្ព័ន្ធប្រពៃណីនៃតំបន់ជនបទភាគច្រើន ដែលផ្អែកលើដីធ្លី និងឋានៈសង្គមនោះកំពុងតែទទួលរងនូវការផ្លាស់ប្តូរ ដោយសារតែមានការអប់រំ ការធ្វើប្រពលវប្បកម្មរចនាសម្ព័ន្ធការងារ និងកម្មវិធីសុខមាលភាព/ការអភិវឌ្ឍរបស់រដ្ឋាភិបាល ដែលឈានទៅ ជំរុញឱ្យមានតុល្យភាពវណ្ណៈ/ថ្នាក់ថ្មីនៅតាមតំបន់ជនបទរវាងវណ្ណៈ ដែលកាន់កាប់ដីច្រើនលើសលប់តាម ប្រពៃណី និងវណ្ណៈសូទ្រ (Pai, 2002)។ បញ្ហាសំខាន់ទីពីរពាក់ព័ន្ធវរជននៅតាមជនបទ បានកើតចេញពីការ កើនឡើងនូវមនសិការនយោបាយក្នុងចំណោមអ្នកមានវណ្ណៈទាបជាង ដែលឈានទៅដល់ក្រោកឈរឡើងពី សំណាក់អ្នកមានវណ្ណៈទាបទៅតាមប្រពៃណី។ ទិដ្ឋភាពនេះបានបង្កើតឱ្យមានការចងក្រងនយោបាយសង្គម ការកសាងអត្តសញ្ញាណ ធ្វើឱ្យកើនចំនួនអ្នកបោះឆ្នោតនៅក្នុងវណ្ណៈសូទ្រ និងមានការផុសចេញនូវគណបក្ស មួយចំនួនដែលដឹកនាំដោយវណ្ណៈសូទ្រ និងសមាគមផ្សេងៗ។

ការប្រែប្រួលទាំងនេះត្រូវបានគេធ្វើការប្រៀបធៀបជាមួយនឹងការផ្លាស់ប្តូរក្នុងពេលទន្ទឹមគ្នានោះនៅក្នុង សហគមន៍វណ្ណៈសូទ្រ។ អត្រាអនក្ខរកម្មក្នុងចំណោមប្រជាជនក្នុងវណ្ណៈសូទ្របានកើនឡើងកាន់តែលឿននៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨0។ អត្រានេះបានកើនឡើងបន្តិច គឺត្រឹមតែ ៤% រវាងឆ្នាំ១៩៧១ ដល់១៩៨១ ប៉ុន្តែនៅឆ្នាំ ១៨៩១ ដល់ ១៩៩១ កំណើនបានកើនដល់ ៨%- ឡើង ៧% ក្នុងចំណោមបុរស និង ៥%ក្នុងចំណោមស្ត្រី។

ថ្វីបើវាជាការពិតដែលថា អត្រាអក្ខរកម្ម និងការទទួលបាននូវការអប់រំបន្ថែមសម្រាប់ប្រជាជនវណ្ណៈសូទ្រនៅមានកម្រិតទាបខ្លាំងនៅក្នុងតំបន់មួយចំនួននៅក្នុងប្រទេសឥណ្ឌាក៏ដោយ ក៏នេះជាផ្នែកមួយដែលការផ្លាស់ប្តូរ មួយចំនួនបានកើតឡើងចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៧០ មក។ អត្រាចុះឈ្មោះចូលរៀនក៏មានការកើនឡើង ដែរនៅក្នុងអំឡុងទសវត្សរ៍នេះ។ ជាងនេះទៀតនោះ ក៏មានរបាយការណ៍បង្ហាញផងដែរពីការលូតលាស់នៃ ល័ក្ខខ័ណ្ឌសេដ្ឋកិច្ចនៅក្នុងវណ្ណៈសូទ្រនៅក្នុងតំបន់មួយចំនួននៃប្រទេស ដែលការនេះបានផ្តល់ឱ្យពួកគេនូវសក្តា នុពលដើម្បីងើបបះបោរប្រឆាំងនឹងការគាបសង្កត់ពីសំណាក់អ្នកមានវណ្ណៈខ្ពស់ជាង។ ឧទាហរណ៍ នៅក្នុង UP ការសិក្សាបានចង្អុលបង្ហាញពីការរីកចម្រើននៃល័ក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមរបស់វណ្ណៈសូត្រចាប់តាំងពីចុងទសវត្សរ៍ ឆ្នាំ១៩៧០។ UP ភាគខាងកើត បដិវត្តិបៃតងដែលនាំទៅឱ្យមានការកើនឡើងនូវការធ្វើវិនិយោគក្នុងវិស័យ កសិកម្ម និងនគរូបនីយ-កម្ម ធ្វើឱ្យឱកាសការងារកើនឡើងក្នុងផ្នែកកសិដ្ឋាន ការងារឡេតដ្ឋ ការងារសាសង់ រតីរម៉កនៅក្នុងទីក្រុង ធ្វើឱ្យបំបាត់ចោលនូវការពឹងផ្អែកទាំងស្រុងទៅលើម្ចាស់ដី និងការជាប់ទាក់ទងជាមួយ អតិថិជន-អ្នកផ្គត់ផ្គង់ (Shankar, 1993)។ នៅតំបន់ទំនាបភាគខាងលិច ជាកន្លែងដែលស្ថានភាពរបស់វណ្ណៈ សូទ្រមានភាពល្អប្រសើរហើយនោះ មានការផ្លាស់ប្តូរដ៏សំខាន់មួយ គឺការងាកចេញពីរឿងដីធ្លីទៅរកប្រភព ផ្សេងៗនៃការប្រកបរបរចិញ្ចឹមជីវិត។ ដោយសារមានការរីកលូតលាស់ផ្នែកការអប់រំ ចំនួនវរជនមានជំនាញ និងសហគ្រិននៅតាមទីប្រជុំជនតូចៗ មានការកើនឡើង ដែលបានធ្វើឱ្យមានការប្រើប្រាស់កូតាការងារដើម្បី ជំនួសការងារមិនមែនកសិកម្ម។

ភាគរយនៃការបោះឆ្នោតក្នុងចំណោមប្រជាជនក្នុងវណ្ណៈសូទ្រក៏បានកើនឡើងដែរ ហើយមានកំណើនលឿនជាងក្នុងចំណោមប្រជាពលរដ្ឋទូទៅ។ នៅក្នុងតំបន់ភាគច្រើន វណ្ណៈសូទ្របានបោះឆ្នោតជាលើកទីមួយចាប់ តាំងពីទទួលបានឯករាជ្យមក។ ការរីករាលដាលនៃអំណាចក្នុងការបោះឆ្នោតបានក្លាយទៅជាមធ្យោបាយ យ៉ាងសំខាន់មួយក្នុងការបង្កើនទំនុកចិត្ត ដើម្បីធ្វើការប៉ះបោរប្រឆាំងទល់នឹងការគ្រប់ដណ្តប់របស់វណ្ណៈខ្ពស់ជាង។ នៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៦ ភាគរយនៃអ្នកបោះឆ្នោតនៅក្នុងវណ្ណៈសូទ្របានបង្ហាញឱ្យឃើញនៅ ឯថ្នាក់រដ្ឋមានចំនួន ៨៧.៣ % ហើយតួលេខប្រហាក់ប្រហែលគ្នានេះដែរសម្រាប់ប្រជាជនក្នុងវណ្ណៈខ្ពស់បំផុត គឺ ៨៥.៦%។ ការបោះឆ្នោតនៅក្នុងឆ្នាំ ១៩៩៨ វត្តមានអ្នកបោះឆ្នោតនៅក្នុងវណ្ណៈសូទ្របានកើនឡើងរហូតដល់ ៩៣% ហើយនៅទូទាំងប្រទេសទាំងមូលបានឡើងដល់៩១.៩%។ តួលេខទាំងនេះបានបង្ហាញនូវសារៈសំខាន់ ព្រោះយើងសម្គាល់ឃើញថាចំនួនវត្តមានអ្នកបោះឆ្នោតនៅក្នុងវណ្ណៈសូទ្រក្នុងឆ្នាំ១៩៧១ មានត្រឹមតែ ៧៨.៧% (Pushpendra, 1999: 2611) នោះ។ និយាយជារួម នៅត្រឹមទសវត្សរ៍ឆ្នាំ១៩៩០ អ្នកប្រាជ្ញ មួយចំនួនធំបានតម្រង់គោលដៅឆ្ពោះទៅបង្កើនចំនួនអ្នកសាធារណៈរដ្ឋថ្មី អ្នកមានការអប់រំ និងអ្នកជំនាន់ក្រោយដែលមានការផ្លាស់ប្តូរឆ្ពោះទៅមុខ ក្នុងចំណោមវណ្ណៈសូទ្រជាមួយនឹងមនសិការកម្រិតខ្ពស់ចំពោះ អត្តសញ្ញាណ ហើយត្រូវបានគេរៀបចំ

ដើម្បីទប់ទល់ជាមួយការគ្រប់គ្រង និងការគាបសង្កត់។ ទោះជាយ៉ាងណាក៏ដោយ ការផ្លាស់ប្តូរទាំងនេះបានកើតឡើងនៅតែក្នុងតំបន់តិចតួចប៉ុណ្ណោះទូទាំងផ្ទៃប្រទេស ល្បឿននៃការផ្លាស់ប្តូរមានដំណើរយឺត និងនៅតែមានភាពក្រីក្រ។ បញ្ហាទីពីរ មានតែមួយផ្នែកតូចប៉ុណ្ណោះនៅក្នុង ចំណោមវណ្ណៈសូទ្រក្នុងតំបន់នីមួយៗបានទទួលផលប្រយោជន៍ពីការវិវឌ្ឍរីកចម្រើនទាំងនេះ ប៉ុន្តែចំនួនភាគ ច្រើនបំផុតនៃប្រជាជននៅក្នុងវណ្ណៈសូទ្រមិនអាចទទួលបានផលប្រយោជន៍ពីការផ្លាស់ប្តូរនេះឡើយ ដោយហេតុថា ពួកគេមិនមានតួនាទីសំខាន់។ លើសពីនេះទៅទៀត ការកែប្រែនយោបាយ និងសង្គមបែបនេះមិន អាចនឹងធ្វើឱ្យពួកគេមានការចាប់អារម្មណ៍ភ្លាមៗនៅតាមថ្នាក់ក្រុមប្រឹក្សាភូមិ។ វាកាន់តែមានការលំបាក សម្រាប់អ្នកដឹកនាំវណ្ណៈសូទ្រក្នុងការជ្រាតខ្លួនចូល ហើយធ្វើការណែនាំឱ្យមានការផ្លាស់ប្តូរនៅតាមថ្នាក់ភូមិ ជាងនៅថ្នាក់ជាតិ ឬ ថ្នាក់រដ្ឋ ឬ សូម្បីតែនៅថ្នាក់ស្រុក។ បញ្ហានេះ គឺដោយសារតែនៅថ្នាក់ភូមិ ប្រជាជន ក្នុងវណ្ណៈសូទ្រធ្លាប់ទទួលរងការគាបសង្កត់ខ្លាំងក្លាបំផុត ហើយក្រុមប្រឹក្សាភូមិ គឺជាអ្នកដែលងាយនឹងទទួល រងគ្រោះបំផុត។

ទិដ្ឋភាពសំខាន់មួយផ្សេងទៀតនោះ គឺថាសេចក្តីត្រូវការឱ្យមានការរួមបញ្ចូលគ្នានៃវណ្ណៈសូទ្រ គឺកាន់តែមានភាពខ្លាំងក្លាឡើងនាពេលបច្ចុប្បន្ននេះ។ ការធ្វើធម្មនុញ្ញវូបនីយកម្មក្រុមប្រឹក្សាភូមិបានបង្កើតឱ្យមានថ្នាក់ចំនួន ៣ នៃរបបសហព័ន្ធនិយម មានអំណាចកាន់តែធំ និងការទទួលខុសត្រូវក្នុងផ្នែកហិរញ្ញវត្ថុ និងការអភិវឌ្ឍ ក្រោមការគ្រប់គ្រងរបស់ស្ថានប័នទាំងនេះ។ ដោយមានការណែនាំឱ្យធ្វើកំណែទម្រង់សេដ្ឋកិច្ចនៅថ្នាក់រដ្ឋនៅ ពាក់កណ្តាលទសវត្សរ៍ទី ៩0 ធ្វើឱ្យមានការទទួលស្គាល់កាន់តែកើនឡើងក្នុងចំណោមអ្នកប្រាជ្ញ និង អ្នកបង្កើតគោលនយោបាយ ដែលក្នុងនោះកម្មវិធីការងារសម្រាប់ប្រជាជនក្រីក្រ សេវាសង្គមជាមូលដ្ឋាន PDS សន្តិសុខសង្គមត្រូវបានអនុវត្តន៍យ៉ាងល្អបំផុតតាមបរិបទវិមជ្ឈការ ដោយស្ថាប័ន PRIs ជាមួយនឹងការចូលរួម ពីសហគមន៍ ដោយស្ថិតនៅក្រោមការទទួលខុសត្រូវរបស់មូលដ្ឋាន (Guhan, 1995: 248)។ ទិដ្ឋភាពនេះ បានទទួលនូវគ្រឹះឆ្លើយតបទៅនឹងការបរាជ័យនៃការគ្រប់គ្រងថ្នាក់រដ្ឋមួយចំនួន ជាពិសេសការគ្រប់គ្រងនៅ ក្នុងរដ្ឋ ដែលដើរថយក្រោយនៅភាគខាងជើងក្នុងការឆ្លើយបតទៅនឹងតម្រូវការជាក់ស្តែងនៃប្រជាជនរបស់ពួកគេ ជាពិសេសក្រុមវណ្ណៈទាបបំផុត។ ដើម្បីណែនាំឱ្យមានការផ្លាស់ប្តូរទាំងនេះ ការកែប្រែអំណាចកាន់តែធំ ត្រូវបានធ្វើចំពោះស្ថានប័ន PRIs ឱ្យធ្វើការលុបបំបាត់ចោលនូវអំពើពុករលួយ និងភាពគ្មានប្រសិទ្ធភាព ហើយតម្រូវឱ្យមានការទទួលខុសត្រូវ និងការចូលរួមក្នុងកម្រិតកាន់តែខ្ពស់ជាងមុន។ ការអនុមត្តិវិសោធន កម្មរដ្ឋធម្មនុញ្ញលើកទី ៧៣ នៅក្នុងឆ្នាំ១៩៩៣ បានធ្វើការផ្ទេរអំណាចរួចទៅហើយដល់ក្រុមប្រឹក្សាភូមិ នូវវិធីគ្រប់គ្រងរដ្ឋទាំងអស់។ ដូច្នេះហើយ កំណែទម្រង់សេដ្ឋកិច្ច និងកំណែទម្រង់មុខងារក្រុមប្រឹក្សាភូមិត្រូវ បានគេមើលឃើញថា ជាការបំពេញបន្ថែម។ ស្ថិតក្នុងសេនារីយូនេះ ការចូលរួមរបស់វណ្ណៈសូទ្រនៅក្នុងមុខ ងាររបស់ស្ថាប័ន PRIs ចាប់ផ្តើមមានសារៈសំខាន់

ក្នុងការធានាថា ពួកគេត្រូវដាក់បញ្ចូលទៅក្នុងការធ្វើ សេចក្តីសម្រេចចិត្តសំខាន់ៗដែលមានឥទ្ធិពលដល់ការអភិវឌ្ឍ នៅក្នុងតំបន់ជនបទ។

PRIA មានប្រវត្តិសាស្ត្រយ៉ាងវែងក្នុងការចែកអំណាចគ្រប់គ្រងដល់ក្រុមដែលត្រូវបានសង្គមទាត់ចោល ជាពិសេស SC ស្ត្រី និងបុរសក្នុង ST។ ការធ្វើការងារដើម្បីពង្រឹងការគ្រប់គ្រងសហគមន៍ក្រីក្រ ជាពិសេសជាមួយ SC និង ST បានផ្តល់អំណាចឱ្យសហគមន៍ SC និង ST ធ្វើការចូលរួម និងត្រួតពិនិត្យការផ្តល់សេវាកម្ម ដោយរដ្ឋាភិបាលមូលដ្ឋាន។ ហើយវាក៏ជាការធានាផងដែរថា មូលនិធិផ្សេងៗដែលរដ្ឋាភិបាលមានត្រូវតែ បង្ហាញឱ្យដឹងដើម្បីឆ្លើយបតទៅនឹងតម្រូវការរបស់ SC និង ST។

## ឯកសារយោង


Beteille, A. 1974, ការសិក្សាពីរចនាសម្ព័ន្ធសង្គមកសិករ, New Delhi: Oxford university Press

Chakraborty, K and S. Bhattacharyya, 1993, ក្រុមអ្នកដឹកនាំ PR: ករណីសិក្សារបស់ West Bengal, Jaipur and New Delhi: ការបោះពុម្ពផ្សាយរបស់ Rawat.

Guhan, S., 1995, មជ្ឈមណ្ឌល និងរដ្ឋនៅក្នុងដំណើរការកែទម្រង់នៅកន្នុងប្រទេសឥណ្ឌា នៅក្នុង Robert Cassen និង Vijay Joshi (eds.) អនាគតនៃការធ្វើកំណែទម្រង់, New Delhi: Oxford University Press

Mendelshohn, O., 1993, ការផ្លាស់ប្តូរអំណាចនៅតាមតំបន់ជនបទរបស់ប្រទេសឥណ្ឌា, ការសិក្សាពីទ្វីបអាស៊ីទំនើប, Vol 27, No 4

Pai, S., 2000, ការជ្រាតខ្លួនចូលរបស់វណ្ណៈសូទ្រ និងការធ្វើបដិវត្តន៍របបប្រជាធិតេយ្យមិនទាន់ពេញចេញ, New Delhi: Sage Publishing

Pushpendra, 1999, ការជ្រាតខ្លួនចូលរបស់វណ្ណៈសូទ្រតាមរយៈគោលនយោបាយធ្វើការបោះឆ្នោត , ការសែតសេដ្ឋកិច្ច និងនយោបាយប្រចាំសាប្តាហ៍, វ៉ុល XXXIV, លេខ 36

Shankar, K., 1998, ពលករកសិកម្មនៅភាគខាងកើត UP, ការសែតសេដ្ឋកិច្ច និងនយោបាយប្រចាំសាប្តាហ, ថ្ងៃទី 12 មិថុនា

Shiviah, M. et al., 1980, ការបោះឆ្នោត Panchayati Raj Elections នៅភាគខាងលិច Bengal 1978: ការសិក្សាពីការកសាងស្ថាប័នសម្រាប់ធ្វើការអភិវឌ្ឍតំបន់ជនបទ, Hyderabad: ស្ថាប័នជាតិសម្រាប់ការអភិវឌ្ឍជនបទ.

Srinivas, MN. 1966, ការផ្លាស់ប្តូរសង្គមនៅក្នុងប្រទេសឥណ្ឌាសម័យទំនើប, Berkeley: University of California Press


ប្រភព : កែសម្រួលពី Kumar, N. and R, Rai (2006) ភាពជាអ្នកដឹកនាំរបស់វណ្ណៈសូទ្រក្នុងក្រុមប្រឹក្សាភូមិ: ការសិកស្សាប្រៀបធៀបនៅក្នុងរដ្ឋចំនួន ៤, New Delhi: ការបោះពុម្ពផ្សាយរបស់ Rawat.